**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

| | | |
|---|---|---|
| សំណុំរឿងលេខ | : | ០០២/១៩-០៩-២០០៧-អវតក/អជសដ |
| ដាក់ទៅ | : | អង្គជំនុំជម្រះសាលាដំបូង |
| ថ្ងៃដាក់ | : | ថ្ងៃទី៦ ខែតុលា ឆ្នាំ២០១១ |
| ភាគីអ្នកដាក់ | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| ភាសាដើម | : | អង់គ្លេស |

**ឯកសារបកប្រែ**
**TRANSLATION/TRADUCTION**
ថ្ងៃ ខែ ឆ្នាំ (Date): 06-Oct-2011, 15:24
CMS/CFO: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ប្រភេទឯកសារស្នើឡើងដោយភាគីដាក់ឯកសារ: **សាធារណៈ** ដោយមាន **ឧបសម្ព័ន្ធ ក សម្ងាត់បំផុត**

ចំណាត់ថ្នាក់ឯកសារកំណត់ដោយអង្គជំនុំជម្រះ: សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:

ការពិនិត្យចំណាត់ថ្នាក់ឯកសារបណ្តោះអាសន្នឡើងវិញ:

ឈ្មោះមន្ត្រីដែលបានពិនិត្យ:

ហត្ថលេខា:

# ការបញ្ជាញរបស់សហព្រះរាជអាជ្ញាអន្តរជាតិ ដល់អង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង ០០២ ចូលក្នុងសំណុំរឿង ០០៣ និង០០៤ ដោយមានឧបសម្ព័ន្ធ ក សម្ងាត់បំផុត

**អ្នកដាក់ឯកសារ:**
សហព្រះរាជអាជ្ញាអន្តរជាតិ:
លោក Andrew CAYLEY

**អ្នកទទួលឯកសារ:**
អង្គជំនុំជម្រះសាលាដំបូង:
ចៅក្រម និល ណុន, ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម យូរ ឧត្តរា

សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី:
លោក ពេជ អង្គ
Elisabeth SIMONNEAU FORT

**ចម្លងជូន:**
សហព្រះរាជអាជ្ញាជាតិ:
លោកស្រី ជា លាង

ជនជាប់ចោទ:
នួន ជា
អៀង សារី
អៀង ធីរិទ្ធ
ខៀវ សំផន

មេធាវីការពារក្តីជនជាប់ចោទ:
លោក សុន អរុណ

| | |
|---|---|
| **ការិ.សហចៅក្រមស៊ើបអង្កេត:** | លោក Michiel PESTMAN |
| ចៅក្រម យូ ប៊ុនឡេង | លោក Victor Koppe |
| ចៅក្រម Siegfried BLUNK | លោក អាង ឧត្តម |
| | លោក Michael G.KARNAVAS |
| | លោក ផាត់ ពៅស៊ាង |
| | កញ្ញា Diana ELLIS QC |
| | លោក ស សូវាន |
| | លោក Jacques VERGÈS |

## I. សេចក្តីផ្តើម

១- តាមរយៈការដាក់ឯកសារនេះ សហព្រះរាជអាជ្ញាអន្តរជាតិស្វែងរកសេចក្តីណែនាំពីអង្គជំនុំជម្រះសាលាដំបូង ទាក់ទងនឹងកំណត់ហេតុស្តាប់ចម្លើយសាក្សីនៃសំណុំរឿង០០២ ដែលបានធ្វើឡើងនៅក្នុងកិច្ចដំណើរការស៊ើបអង្កេត ចូលទៅក្នុងសំណុំរឿងលេខ០០៣ និង០០៤។ សាក្សីទាំងនេះត្រូវបានជ្រើសរើសសម្រាប់ផ្តល់សក្ខីកម្មផ្ទាល់មាត់ដោយអង្គជំនុំជម្រះសាលាដំបូង ឬស្នើឡើងដោយសហព្រះរាជអាជ្ញា ដើម្បីផ្តល់សក្ខីកម្ម ឬមួយកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគាត់ត្រូវបានទទួលយកធ្វើជាភ័ស្តុតាងនៅពេលសវនាការ។ នៅក្រោមវិធានផ្ទៃក្នុងសម្រាប់ អវតក និងនីតិវិធីដែលបានបង្កើតឡើងនៅកម្រិតអន្តរជាតិចំពោះករណីស្រដៀងគ្នានេះ គេតម្រូវឲ្យដាក់បង្ហាញនូវចម្លើយបែបដូច្នេះនៅលើមូលដ្ឋានដែលថា ចម្លើយទាំងនេះ (១) អាចមានឯកសារដោះបន្ទុក ឬឯកសារដែលអាចប៉ះពាល់ដល់ភាពគួរឲ្យជឿបាននៃសក្ខីកម្មរបស់សាក្សី, និង (២) ជាចម្លើយពីមុនរបស់សាក្សីរូបណាមួយនៅសវនាការ។

២- **ឧបសម្ព័ន្ធ** ក បានដាក់ឈ្មោះសាក្សីចំនួន២៩នាក់ នៅក្នុងសំណុំរឿង០០២ ដែលបានផ្តល់នូវកំណត់ហេតុស្តាប់ចម្លើយ ចូលទៅក្នុងសំណុំរឿង០០៣ និង០០៤។ ដើម្បីធានាឲ្យប្រាកដថា សហចៅក្រមស៊ើបអង្កេតបានដឹងពីបញ្ហានេះ សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់បញ្ចូលកំណត់ហេតុទាំងនេះទៅក្នុងបញ្ជីអ្នកទទួលឯកសារនៅក្របទំព័រនៃឯកសារដែលដាក់ជូននេះ។

## II. ប្រវត្តិនីតិវិធី

៣- សហព្រះរាជអាជ្ញាបានដាក់បញ្ជីឈ្មោះសាក្សីបឋមរបស់ខ្លួនដែលបានស្នើសម្រាប់សំណុំរឿង០០២ នៅថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១[1]។ ឧបសម្ព័ន្ធនានាដែលបានភ្ជាប់ជាមួយនឹងការដាក់ឯកសារនោះ បានកំណត់អត្តសញ្ញាណកំណត់ហេតុសាក្សីមុនៗ ដែលបានស្នើឡើងសម្រាប់សវនាការទៅតាមការយល់

[1] បញ្ជីឈ្មោះអ្នកជំនាញ សាក្សី និង ដើមបណ្តឹងរដ្ឋប្បវេណី របស់សហព្រះរាជអាជ្ញា រួមទាំងឧបសម្ព័ន្ធសម្ងាត់, ថ្ងៃទី២៨ មករា ២០១១, E9/4 (“បញ្ជីឈ្មោះសាក្សីសម្រាប់សវនាការ របស់សហព្រះរាជអាជ្ញា”) ។

ដឹងរបស់សហព្រះរាជអាជ្ញានាពេលនោះ។ នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០១១ សហព្រះរាជអាជ្ញា បានដាក់បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា សម្រាប់សវនាការស្របតាមវិធាន៨០.៣[2]។ ឧបសម្ព័ន្ធ ១២ នៃបញ្ជីឈ្មោះនេះមានកំណត់ហេតុស្តាប់ចម្លើយសាក្សីចំនួន១៤១៥ ដែលសហព្រះរាជអាជ្ញាមាន បំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះនៅពេលសវនាការ។ នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១១ អង្គជំនុំជម្រះសាលាដំបូងបានចេញបញ្ជីឈ្មោះសាក្សីបណ្តោះអាសន្ន សម្រាប់ដំណាក់កាលដំបូងនៃ សវនាការ ដោយបានកំណត់អត្តសញ្ញាណសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីចំនួន៥៦ រូប។

៤- ជាបន្តបន្ទាប់ពីការដាក់បញ្ជីឈ្មោះសាក្សី សម្រាប់សវនាការរបស់ការិយាល័យសហព្រះរាជអាជ្ញា សហចៅក្រមស៊ើបអង្កេតបានស្តាប់យកចម្លើយសាក្សីនានា និងបានដាក់ចូលទៅក្នុងសំណុំរឿង០០៣ និង០០៤នូវកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីចំនួនដប់បីនាក់ ដែលមាននៅក្នុងបញ្ជីឈ្មោះសាក្សី សម្រាប់សវនាការរបស់ការិយាល័យសហព្រះរាជអាជ្ញា នៅក្នុងសំណុំរឿង០០២។ ភាគច្រើនបំផុត នៃបទសម្ភាសន៍ទាំងនេះបានកើតមានឡើងនៅក្នុងរយៈពេលប្រាំខែចុងក្រោយនេះ។ ជាពិសេស ក្នុង ចំណោមកំណត់ហេតុស្តាប់ចម្លើយចំនួន៣៦ដែលបានធ្វើឡើងដល់ទីកន្លែង ដោយអ្នកស៊ើបអង្កេតរបស់ កសចស នៅក្នុងសំណុំរឿង០០៣ និង០០៤ នៅចន្លោះខែមិថុនា និងខែធ្នូ ឆ្នាំ២០១០ មានតែកំណត់ ហេតុស្តាប់ចម្លើយតែមួយគត់នៃកំណត់ហេតុទាំង៣៦ បានជាប់ពាក់ព័ន្ធទៅនឹងសាក្សីម្នាក់ដែលបាន ស្នើឡើង ក្នុងបញ្ជីសាក្សីសម្រាប់សវនាការរបស់សហព្រះរាជអាជ្ញា ក្នុងសំណុំរឿង០០២។

៥- យ៉ាងណាក៏ដោយ នៅក្នុងបទសម្ភាសន៍ដែលបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិ ចាប់តាំងពីចុងខែមីនា ឆ្នាំ២០១១ មានសាក្សីចំនួន១២នាក់ ក្នុងចំណោមសាក្សីចំនួន៣៤នាក់ ដែលត្រូវ បានស្តាប់ចម្លើយដោយចៅក្រម Blunk នោះ គឺជាសាក្សីសម្រាប់សវនាការដែលបានស្នើឡើងដោយ ការិយាល័យសហព្រះរាជអាជ្ញា ដែលក្នុងចំនួននោះមានបួននាក់គឺជាផ្នែកនៃសាក្សីចំនួន៥៦នាក់ ដែល អង្គជំនុំជម្រះសាលាដំបូងបានជ្រើសរើសបណ្តោះអាសន្ន សម្រាប់ដំណាក់កាលដំបូងនៃសវនាការ។ អ្នកដទៃទៀត គឺជាសាក្សីសម្រាប់សវនាការដែលការិយាល័យសហព្រះរាជអាជ្ញាបានស្នើឡើងទាក់ទង ទៅនឹងមូលដ្ឋានឧក្រិដ្ឋកម្មនៃសំណុំរឿង០០២។ បន្ថែមលើនេះ មានសក្សីចំនួន១៦នាក់បន្ថែមទៀត

[2] បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា សម្រាប់សវនាការស្របតាមវិធាន ៨០.៣, ថ្ងៃទី១៩ មេសា ២០១១, E9/31 ("បញ្ជីឯកសារសម្រាប់ សវនាការ របស់សហព្រះរាជអាជ្ញា") ។

ដែលត្រូវបានធ្វើសម្ភាសន៍នៅក្នុងសំណុំរឿង០០៣ និង០០៤ ដែលត្រូវបានស្នើឡើងដោយសហព្រះរាជអាជ្ញា តែឯងដើម្បីឱ្យទទួលយកនូវកំណត់ហេតុស្តាប់ចម្លើយរបស់ពួកគេធ្វើជាភ័ស្តុតាងនៅសវនាការ។

## III. អំពីច្បាប់

### *i. ការដាក់បង្ហាញឯកសារដោះបន្ទុក*

៦- វិធាន ២១.១ បានតម្រូវជាទូទៅឱ្យមានការដាក់បង្ហាញឯកសារដោះបន្ទុក និងយ៉ាងជាក់លាក់ ដោយវិធាន៥៣.៤។ វិធាន ២១.១.ក ចែងថា ដំណើរការនីតិវិធីនៅ អវតក ត្រូវតែមាន "យុត្តិធម៌ និងត្រូវគោរពគោលការណ៍ចំពោះមុខ ហើយត្រូវរក្សាបាននូវតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងឡាយ"។ វិធាន ៥៣.៤ បានតម្រូវបន្ថែមទៀតថា សហព្រះរាជអាជ្ញាត្រូវបង្ហាញទៅសហចៅក្រមស៊ើបអង្កេត នូវសម្ភារៈទាំងឡាយដែលសហព្រះរាជអាជ្ញាបានដឹង ហើយដែលសម្ភារៈទាំងនេះនឹងអាចនាំឱ្យគ្មានពិរុទ្ធភាព ឬសម្រាលពិរុទ្ធភាពនៃជនសង្ស័យ ឬជនត្រូវចោទ ឬធ្វើឱ្យប៉ះពាល់ដល់ភាពជឿជាក់នៃភ័ស្តុតាងក្នុងការចោទប្រកាន់។ នេះគឺជាការបន្ថែមទៅនឹងវិធាន ៥៣.២ និងនៅហួសពីការដាក់បង្ហាញដំបូងនៃឯកសារដោះបន្ទុកដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរទៅទៀត។ សហព្រះរាជអាជ្ញាអន្តរជាតិជូនសេចក្តីសន្និដ្ឋានថា ដោយអនុលោមតាមសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការកាត់សេចក្តីដ៏ត្រឹមត្រូវ កាតព្វកិច្ចនេះត្រូវបន្តនៅគ្រប់ដំណាក់កាលទាំងអស់នៃកិច្ចដំណើរការនីតិវិធីនៅ អវតក នេះ។

៧- វិធីសាស្ត្រនេះត្រូវគ្នាទៅនឹងយុត្តិសាស្ត្ររបស់តុលាការព្រហ្មទណ្ឌអន្តរជាតិនានា។ ឧទាហរណ៍ វិធាន ៧៧ នៃវិធានភ័ស្តុតាង និងនីតិវិធី (RoPE) របស់តុលាការអចិន្ត្រៃយ៍ព្រហ្មទណ្ឌអន្តរជាតិ (ICC) បានផ្តល់សិទ្ធិឱ្យមេធាវីការពារក្តីធ្វើការត្រួតពិនិត្យលើឯកសារដោះបន្ទុកណាមួយ ដែលមាននៅក្នុងការកាន់កាប់របស់រដ្ឋអាជ្ញា។ ស្រដៀងគ្នានេះដែរ វិធាន ៦៨(i) នៃ RoPE របស់តុលាការ ICTY តម្រូវឱ្យរដ្ឋអាជ្ញា ធ្វើការសម្រួលដល់មេធាវីការពារក្តីឱ្យបាន "ឯកសារណា មួយក៏ដោយដែលរដ្ឋអាជ្ញាបានដឹងឮនោះ អាចនាំឱ្យគ្មានពិរុទ្ធភាព ឬសម្រាលពិរុទ្ធភាពនៃជនជាប់ចោទ ឬធ្វើឱ្យប៉ះពាល់ដល់ភាពជឿជាក់នៃភ័ស្តុតាងក្នុងការចោទប្រកាន់"។ វិធាន ៦៨(ក) របស់តុលាការ ICTR, RoPE បានបង្កើតកាតព្វកិច្ចស្រដៀងគ្នានេះឱ្យទៅខាងរដ្ឋអាជ្ញា។

៨- កាតព្វកិច្ចនេះទាក់ទងទៅនឹងចម្លើយនានាដែលបានធ្វើឡើង នៅក្នុងកិច្ចដំណើរការនីតិវិធីដទៃទៀត និងត្រូវធ្វើបន្តនៅគ្រប់ដំណើរការតាមផ្លូវតុលាការទាំងមូល។ ឧទាហរណ៍ នៅតុលាការ ICTY បន្ទាប់ពីផ្តល់សក្ខីកម្មនៅក្នុងករណីរបស់ *Blaskić* សាក្សីមួយចំនួនក៏បានផ្តល់ភ័ស្តុតាងនៅក្នុងករណីពាក់ព័ន្ធមួយផងដែរ។ ដើមបណ្តឹងឧទ្ធរណ៍បានដាក់សំណើសុំបង្ហាញសក្ខីកម្មរបស់ខ្លួន នៅលើទឡ្ហីករណ៍មួយចំនួន ដោយរួមទាំងវិធាន ៦៨(i)។ អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY បានសម្រេចថា វិធាននេះបានដាក់កាតព្វកិច្ចដែលត្រូវបន្តធ្វើនៅគ្រប់ដំណាក់កាលនៃការជំនុំជម្រះ និងនៅដំណាក់កាលនៃបណ្តឹងឧទ្ធរណ៍ ហើយដែលគ្របដណ្តប់ទៅលើចម្លើយដោះបន្ទុកនានាដែលបានធ្វើឡើងនៅក្នុងកិច្ចដំណើរការដទៃទៀត។ គេបានថ្លែងបន្តទៀតថា កាតព្វកិច្ចនេះក៏បានកើតចេញមកពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការកាត់សេចក្តីដ៏ត្រឹមត្រូវផងដែរ ហើយស្ថានភាពរបស់រដ្ឋអាជ្ញាមាននៅក្នុងឋានៈជា “អង្គភាព” មួយរបស់តុលាការ និងរបស់យុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិ[3]។

*ii. ការដាក់បង្ហាញចម្លើយពីមុនៗរបស់សាក្សី*

៩- បញ្ហានៃការដាក់បង្ហាញចម្លើយពីមុនៗរបស់សាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធី មិនត្រូវបានដោះស្រាយឲ្យបានច្បាស់លាស់នៅក្នុងវិធានផ្ទៃក្នុង ឬនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជាទេ។ ជាផលវិបាក ដោយអនុលោមតាមមាត្រា៣៣ថ្មី នៅក្នុងកាលៈទេសៈបែបដូច្នេះ កាលណា “នីតិវិធីដែលមានស្រាប់ ពុំបានចែងពីករណីពិសេសមួយ” គេអាចស្វែងរកការណែនាំក្នុងវិធាននីតិវិធីដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ។ វិធាន៦៦(ក)(ii) សម្រាប់តុលាការ ICTY និង ICTR បាន ដាក់កាតព្វកិច្ចដល់រដ្ឋអាជ្ញាឲ្យធ្វើការសម្រួលដល់មេធាវីការពារក្តីឲ្យបានសំណៅចម្លងនៃចម្លើយរបស់សាក្សីទាំងអស់ ដែលរដ្ឋអាជ្ញាមានបំណងធ្វើការកោះហៅនៅពេលសវនាការ ឬដែលគេត្រូវទទួលយកជាជំនួសឲ្យសក្ខីកម្មផ្ទាល់មាត់។ នៅក្នុងករណីរបស់ *Blaskić* អង្គជំនុំជម្រះសាលាឧទ្ធរណ៍បានសម្រេចថា រដ្ឋអាជ្ញាមិនត្រូវបានភ្ជាប់កាតព្វកិច្ចឲ្យដាក់បង្ហាញចម្លើយពីមុនៗរបស់សាក្សីទេ ដោយហេតុថា រដ្ឋអាជ្ញាមិនអាចមាន

[3] *រដ្ឋអាជ្ញា ទល់នឹង Tihomir Blaškić*, សំណុំរឿងលេខ IT-95-14-A, សាលដីកាលើញត្តិរបស់ដើមបណ្តឹងឧទ្ធរណ៍ ស្នើសុំផលិតឯកសារ, ការផ្អាក ឬ ការពន្យារកាលវិភាគធ្វើសារណា និង ការដាក់ឯកសារផ្សេងៗទៀត (អង្គជំនុំជម្រះសាលាឧទ្ធរណ៍នៃតុលាការ ICTY), ថ្ងៃទី២៦ កញ្ញា ២០០០, កថាខណ្ឌទី ៣១-៣៣ ។

"ចេតនា" នៅក្នុងការកោះហៅសាក្សីនានាដែលបានផ្តល់សក្ខីកម្មរួចហើយនៅសវនាការលើបណ្តឹងឧទ្ធរណ៍នោះទេ។ យ៉ាងណាក៏ដោយ ពួកគាត់បានសម្រេចថា បើសាក្សីរូបណានៅមិនទាន់បានផ្តល់សក្ខីកម្មនៅឡើយទេ រដ្ឋអាជ្ញាត្រូវធ្វើការដាក់បង្ហាញចម្លើយនានាដែលបានធ្វើនៅក្នុងកិច្ចដំណើរការនីតិវិធីដទៃទៀត[4]។

១០- កាតព្វកិច្ចក្នុងការបង្ហាញជូននូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនានាពីមុនៗ រួមមាន ចម្លើយសាក្សីទាំងឡាយ ដែលត្រូវបានយកដោយអង្គភាពនានាក្រៅពីអយ្យការ។ នៅក្នុងករណីរឿងក្តីរបស់ *Milutinović* នៅតុលាការ ICTY រដ្ឋអាជ្ញាបានបង្គាប់ឲ្យបង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយនានា និងបទសម្ភាសន៍របស់ជនភៀសខ្លួនដែលប្រមូលបានដោយអង្គការអន្តរដ្ឋាភិបាល និងមិនមែនរដ្ឋាភិបាលនានាជាច្រើន[5]។ អង្គជំនុំជម្រះសាលាដំបូងបានសម្រេចថា ចម្លើយសាក្សីណាម្នាក់រួមមានការ "រៀបរាប់អំពីរឿងរ៉ាវដែលបុគ្គលណាម្នាក់បានដឹងអំពីឧក្រិដ្ឋកម្មដែលត្រូវបានធ្វើកំណត់ហេតុត្រឹមត្រូវទៅតាមនីតិវិធីនៅក្នុងអម្លុងពេលនៃកិច្ចស៊ើបសួរ" ដោយមិនប្រកាន់ថាតើកំណត់ហេតុនោះបានមកដោយរដ្ឋអាជ្ញាផ្ទាល់ ឬមួយក៏តាមរយៈប្រភពផ្សេងៗទៀតនោះឡើយ[6]។ វិសាលភាពនៃកាតព្វកិច្ចនេះត្រូវបាននិយាយជាថ្មីឡើងវិញថាកើតចេញមកពីឋានៈរបស់រដ្ឋអាជ្ញា ដែលក្នុងនាមជា "ស្ថាប័នគ្រប់គ្រងយុត្តិធម៌ព្រហ្មទណ្ឌអន្តរជាតិមួយ" និងមកពីសិទ្ធិរបស់ជនជាប់ចោទក្នុងការទទួលបាននូវការជំនុំជម្រះក្តីមួយដោយត្រឹមត្រូវ[7]។

## IV. ឧទ្ធរណ៍

១១- នៅក្នុងដំណាក់កាលនេះ នៅក្នុងសំណុំរឿងលេខ០០២ សហព្រះរាជអាជ្ញាមិនអាចបង្ហាញនូវអត្តសញ្ញាណរបស់សាក្សីទាំងម្ភៃប្រាំមួយ(២៦)នាក់នេះ ឬផ្តល់ជូននូវច្បាប់ចម្លងនៃកំណត់ហេតុចម្លើយ

---

[4] *ដដែលដូចមុន,* កថាខណ្ឌទី ១៥-១៦ ។

[5] ករណីរឿងក្តីរបស់ រដ្ឋអាជ្ញា ទល់នឹង *Milan Milutinović និងគូរកន,* សំណុំរឿងលេខ IT-05-87-T, សេចក្តីសម្រេចលើញត្តិរបស់ Ojdanić Motion ដែលស្នើសុំឲ្យបង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សី និងការរកឃើញអំពីការរំលោភលើវិធាន៦៦(ក)(ii) (អង្គជំនុំជម្រះសាលាដំបូងនៃតុលាការ ICTY), ចុះថ្ងៃទី២៩ កញ្ញា ២០០៦,កថាខណ្ឌទី១ និងទី៧។

[6] *ដូចគ្នានឹងខាងលើ* កថាខណ្ឌទី១៤ និងទី១៩។

[7] *ដូចគ្នានឹងខាងលើ* កថាខណ្ឌទី១៣ និងទី១៦។

របស់ពួកគេជូនភាគីដទៃៗទៀតបានទេ ព្រោះដោយសារកាតព្វកិច្ចត្រូវរក្សាការសម្ងាត់របស់សហព្រះរាជអាជ្ញានៅក្នុងពេលដែលកិច្ចស៊ើបសួរកំពុងតែបន្តធ្វើនៅក្នុងសំណុំរឿងលេខ០០៣ និង០០៤។ ទោះជាយ៉ាងណាក្តី សហព្រះរាជអាជ្ញាអន្តរជាតិជឿថា ខ្លួនមានកាតព្វកិច្ចត្រូវជូនដំណឹងដល់អង្គជំនុំជម្រះសាលាដំបូង ដោយផ្អែកលើមូលដ្ឋាននៃការ ***ទុកជាការសម្ងាត់បំផុត*** នូវឈ្មោះរបស់សាក្សីទាំងនេះដែលមាននៅក្នុង**ឧបសម្ព័ន្ធ ក** និងភាគីផ្សេងៗទៀតនៃសំណុំរឿងលេខ០០២ដែលជាទូទៅជាងនេះ អំពីអត្ថិភាពនៃកំណត់ហេតុស្តាប់ចម្លើយសាក្សីទាំងនេះ។ ដើម្បីឲ្យអង្គជំនុំជម្រះសាលាដំបូងអាចនឹងសម្រេចថា តើចម្លើយទាំងនេះគួរត្រូវបង្ហាញឲ្យដឹងដែរ ឬទេនៅក្នុងករណីនេះ។

១២- សហព្រះរាជអាជ្ញាអន្តរជាតិលើកឡើងថា ការបង្ហាញនូវចម្លើយសាក្សីទាំងនេះគឺជាការចាំបាច់ ព្រោះដោយសារមូលហេតុចំនួនពីរ។ ទីមួយ កម្រិតខ្លឹមសារនៃចម្លើយណាមួយក្នុងចំណោមចម្លើយទាំងនោះមានព័ត៌មានដោះបន្ទុកទាក់ទងនឹងសំណុំរឿងលេខ០០២ ការបង្ហាញគឺតម្រូវតែធ្វើដោយអនុលោមតាមគោលការណ៍ដែលគូសបញ្ជាក់នៅក្នុងវិធាន២១.១ និង៥៣.៤ នៃវិធានផ្ទៃក្នុង ដោយសារចម្លើយទាំងនោះអាចធ្វើឲ្យដឹងអំពីភាពស្លូតត្រង់ ឬអំពីការបន្ធូរបន្ថយពិរុទ្ធភាពរបស់ជនសង្ស័យ ឬជនត្រូវចោទ ឬប៉ះពាល់ទៅលើភាពគួរឲ្យជឿទុកចិត្តនៃភ័ស្តុតាងរបស់អយ្យការ”[8]។ ហេតុដូចនេះ កម្រិតដែលចម្លើយណាមួយចំនួននៅក្នុងសំណុំរឿងលេខ០០៣ និង០០៤ មានរួមបញ្ចូលនូវអង្គហេតុដោះបន្ទុកនានា ឬអាចមានភាពមិនស្របគ្នាណាមួយចំនួនជាមួយនឹងចម្លើយកាលពីមុនៗរបស់សាក្សីទាំងនោះ គឺតម្រូវត្រូវតែបង្ហាញជូននូវចម្លើយទាំងនោះនៅក្នុងសំណុំរឿងលេខ០០២។

១៣- ទីពីរ តាមស្មារតីនៃនីតិវិធីអន្តរជាតិនៅក្នុងករណីរឿងដែលស្រដៀងគ្នានេះ- ការបង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយកាលពីមុនៗរបស់សាក្សីនានា គឺចាំបាច់ត្រូវតែធ្វើដោយខានមិនបាន។ ការអនុវត្តដូចនេះ ជាការទទួលស្គាល់មួយអំពីប្រការដែលថា វាគឺជាផលប្រយោជន៍សម្រាប់យុត្តិធម៌ដែលភាគីនានា និងអង្គជំនុំជម្រះសាលាដំបូងបានកាន់កាប់ក្នុងដៃរបស់ខ្លួននូវចម្លើយទាំងឡាយដែលក្នុងនោះមានព័ត៌មានទាក់ទងនឹងកម្មវត្ថុនៃរឿងក្តីដែលត្រូវធ្វើការជំនុំជម្រះ ទោះជាព័ត៌មានដាក់បន្ទុក ឬដោះ

[8] វិធាន២១ (១) និងវិធាន ៥៣(៤) នៃវិធានផ្ទៃក្នុង។ នៅពេលដែលវិធានក្រោយនេះ គ្រាន់តែយកមកអនុវត្តទៅតាមអាណត្តិរបស់ខ្លួន ត្រឹមតែដំណាក់កាលនៃកិច្ចស៊ើបសួរតែប៉ុណ្ណោះនោះ សហព្រះរាជអាជ្ញាបានបន្តធ្វើលើការសន្មតដែលថា កាតព្វកិច្ចមួយដែលស្រដៀងគ្នានេះមានអត្ថិភាពនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធីនៅចំពោះមុខ អវតក។

បន្ទុកក្តី។ ជាពិសេស ទាក់ទងនឹងបុគ្គលទាំងឡាយដែលនឹងត្រូវចូលបង្ហាញខ្លួនជាសាក្សីសម្រាប់ពេលសវនាការនៅក្នុងករណីរឿងនេះ ការសួរដេញដោលចំពោះសាក្សីទាំងនេះដោយអង្គជំនុំជម្រះសាលាដំបូង និងភាគីនានា មុខជានឹងកាន់តែមានប្រសិទ្ធភាពជាងមុន ហើយទំនងជាកាន់តែធ្វើឲ្យមានការបញ្ជាក់ពីការពិតជាងមុន បើសិនជារាល់ចម្លើយទាំងអស់កាលពីមុនៗទាំងនោះដែលគេធ្លាប់ដឹង គឺទាក់ទងនឹងករណីរឿងនេះត្រូវបានគេធ្វើឲ្យមានស្រាប់ដែលងាយរកបាន។ ស្រដៀងគ្នានេះដែរ ប្រសិនបើកំណត់ហេតុស្តាប់ចម្លើយរបស់សាក្សីដែលសាក្សីនោះមិនត្រូវបានកោះហៅ កំណត់ហេតុនោះចាត់ទុកថាជាភស្តុតាងជាងកំណត់ហេតុស្តាប់ចម្លើយពីមុនៗ ហើយនឹងជួយដល់អង្គជំនុំជម្រះសាលាដំបូង ក្នុងការថ្លឹងថ្លែងទម្ងន់នៃភស្តុតាងដែលពាក់ព័ន្ធ។

១៤- លើសពីនេះ សហព្រះរាជអាជ្ញាអន្តរជាតិបានពិនិត្យឡើងវិញនូវកំណត់ហេតុស្តាប់ចម្លើយថ្មីៗទាំងនេះ ក្នុងសំណុំរឿងលេខ០០២ បានកត់សម្គាល់ឃើញនូវភាពមិនស្របគ្នា ឬចន្លោះប្រហោងមួយចំនួន នៅពេលធ្វើការប្រៀបធៀបចម្លើយសាក្សីនានានៅក្នុងសំណុំរឿងលេខ០០៣ និង០០៤ ទៅនឹងខ្សែអាត់ថតសម្លេងនៃការធ្វើសម្ភាសន៍ទាំងនោះ ហេតុដូចនេះការបង្ហាញជូនណាមួយដោយការណែនាំរបស់អង្គគួរបានរួមបញ្ចូលទាំងខ្សែអាត់ថតសម្លេងនៃការធ្វើសម្ភាសន៍ទាំងនេះផងដែរ។ ពីព្រោះការធ្វើសម្ភាសន៍ទាំងឡាយដែលបានដឹកនាំធ្វើដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិគឺខ្លីៗទេ(ដែលភាគច្រើន គឺមានរយៈពេលតែពី១០ទៅ ៣០នាទីតែប៉ុណ្ណោះ) ការពិនិត្យឡើងវិញនូវកំណត់ហេតុស្តាប់ចម្លើយថ្មីៗ និងខ្សែអាត់ថតសម្លេងទាំងនេះ នឹងមិនធ្វើឲ្យអង្គជំនុំជម្រះ ឬភាគីនានាត្រូវចំណាយពេលច្រើនហួសហេតុពេកនោះឡើយ។

១៥- ក្នុងការធ្វើសំណើនេះ គឺសហព្រះរាជអាជ្ញាអន្តរជាតិបានគិតគូរយកចិត្តទុកដាក់លើភាពចាំបាច់ក្នុងការរក្សាការសម្ងាត់នៃកិច្ចស៊ើបសួរដែលកំពុងតែបន្តធ្វើនៅក្នុងសំណុំរឿងលេខ០០៣ និង០០៤ ដោយអនុលោមតាមវិធាន៥៦.១ និងវិធាន៦០.២ នៃវិធានផ្ទៃក្នុង។ ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងសម្រេចថា ចាំបាច់ត្រូវតែបង្ហាញនូវចម្លើយសាក្សីទាំងនេះ ការសម្ងាត់អាចនឹងរក្សាបានដោយការដាក់ចំណាត់ថ្នាក់ឯកសារទាំងនេះថា ជាការសម្ងាត់បំផុត ហើយកម្រិតឲ្យបង្ហាញឯកសារទាំងនេះជូនតែភាគីទាំងឡាយណាដែលចាំបាច់បានហើយ។ អង្គជំនុំជម្រះសាលាដំបូងក៏អាចបង្គាប់ឲ្យភាគីនានានៅក្នុងសំណុំ

រឿងលេខ០០២ មិនឲ្យបង្ហាញសាក្សីកំពុងមានបញ្ហានៅពេលសវនាការ គឺសាក្សីនោះជាសាក្សីដែលបានផ្តល់ចម្លើយក្នុងការស៊ើបសួរនៅក្នុងសំណុំរឿងលេខ០០៣ និង០០៤ផងដែរ។

## V. សេចក្តីសន្និដ្ឋាន

១៦- ហេតុដូច្នេះ សហព្រះរាជអាជ្ញាអន្តរជាតិស្នើសុំសេចក្តីណែនាំដោយសេចក្តីគោរព ពីអង្គជំនុំជម្រះសាលាដំបូងទាក់ទងទៅនឹងការបង្ហាញនូវកំណត់ហេតុស្តាប់ចម្លើយសាក្សីនានាដែលបានមកពីសំណុំរឿងលេខ០០៣ និង០០៤ ដាក់ចូលជាសាក្សីក្នុងសំណុំរឿងលេខ០០២ ដូចដែលបានបង្ហាញអត្តសញ្ញាណនៅក្នុង**ឧបសម្ព័ន្ធ** ក ជាការសម្ងាត់បំផុត៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី៦ ខែតុលា ឆ្នាំ២០១១ | **លោក** Andrew CAYLEY<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |